# តើនៅពេលណាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមត្រូវកាត់ទោស? សារសំខាន់នៃករណី០០២

### ដោយ ឆាំង យុ

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

*កាលពីសប្តាហ៍មុន អង្គជំនុំជម្រះវិសាមញ្ញដែលទទួលភារកិច្ចក្នុងការកាត់ទោសចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បានចេញសេចក្តីសម្រេចចុងក្រោយចំពោះករណី០០១។ ករណីនេះ ធ្វើការស៊ើបអង្កេតចំពោះ ឌុច (ឬ កាំង ហ្គិចអ៊ាវ) ជាប្រធានគុកស-២១ ដែលមានមនុស្សប្រមាណ ១៤,០០០នាក់ ត្រូវបានបង្ខំឲ្យផ្តល់ចម្លើយសារភាពដោយការធ្វើទារុណកម្ម និងបន្ទាប់មកត្រូវបានសម្លាប់។ ក្នុងនាមជាមន្ទីរសន្តិសុខធំបង្អស់របស់ខ្មែរក្រហម ភាគច្រើនគឺកម្មាភិបាលខ្មែរក្រហមផ្ទាល់ និងបក្សជនជាច្រើនទៀតត្រូវបានយកមកដាក់ឃុំឃាំងនៅទីនោះ។ ពេញមួយរយៈកាលនៃការធ្វើសវនាការ ឌុច មិនបានបង្ហាញអំពីវិប្បដិសារីចំពោះអំពើរបស់ខ្លួនសោះឡើយ ដែលផ្ទុយស្រឡះពីកាលដែល ឌុច បានសុំខមាទោសពីសំណាក់សាធារណជនតាំងពីការចាប់ផ្តើមសវនាការដំបូងកាលពីខែកុម្ភៈនោះ។ ជាការពិតណាស់ ជនរងគ្រោះជាច្រើនសម្លឹងឃើញការសុំខមាទោសនោះដោយការងឿងឆ្ងល់ ហើយអ្នកជំនាញជាច្រើនក៏យល់ឃើញថា វាគ្រាន់តែជាវិធីសាស្ត្រមួយសម្រាប់បន្ធូរបន្ថយទោសតែប៉ុណ្ណោះ។ ចំណាប់អារម្មណ៍ចុងក្រោយរបស់ ឌុច កាលពីសប្តាហ៍មុនបញ្ជាក់យ៉ាងច្បាស់ចំពោះភាពស្រពិចស្រពិលនេះ និងការប៉ុនប៉ងរបស់ខ្លួន ក្នុងការប្រើប្រាស់សាលាក្តីជាការតស៊ូចុងក្រោយ ចំពោះការជឿជាក់របស់ខ្លួនទៅលើបដិវត្តន៍ខ្មែរក្រហម។ ពាក្យសម្តីនិងគំនិតរបស់ ឌុច នៅតែបង្ហាញយ៉ាងច្បាស់អំពីភាពឃោរឃៅមិនមែនជាមនុស្សនៅក្នុងក្រសែភ្នែកជនរងគ្រោះ ហើយអត្តចរិតរបស់ ឌុច ក៏មិនបានផ្លាស់ប្តូរអ្វីសូម្បីតែបន្តិច។ អង្គជំនុំជម្រះវិសាមញ្ញគួរដាក់ទោស ឌុច អតីតមេគុកទួលស្លែង (ស-២១) ដោយដាក់គុកអស់មួយជីវិត។ នៅក្នុងគុក ឌុច ត្រូវអានចម្លើយសារភាពទាំងអស់ ដែលមាននៅសារមន្ទីរទួលស្លែង។ អានហើយត្រូវទន្ទេញឲ្យចាំទាំងអស់។ ករណីបន្ទាប់របស់តុលាការនេះគឺករណី០០២ ដែលមានសារសំខាន់ខ្លាំងណាស់ ទាំងផ្នែកនយោបាយនិងប្រវត្តិសាស្ត្រ ដោយសារករណីនេះនឹងធ្វើការស៊ើបអង្កេតលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួន៤រូប ដែលនៅរស់រានមានជីវិតដល់បច្ចុប្បន្ននេះគឺ នួន ជា, អៀង សារី, អៀង ធីរិទ្ធ និងខៀវ សំផន។ មានសំណួរជាច្រើនទាក់ទងនឹងការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យដែលមានរយៈកាល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ មិនទាន់បានទទួលចម្លើយនៅឡើយទេ។ អ្នក*

ដឹកនាំជាន់ខ្ពស់ទាំងនេះមិនបានទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មណាមួយ ដែលបានប្រព្រឹត្តឡើងនៅក្នុងរបបនេះឡើយ ផ្ទុយទៅវិញថែមទាំងទម្លាក់កំហុសទៅលើកម្មាភិបាលថ្នាក់ក្រោមនិងមនុស្សផ្សេងទៀត ។ ប៉ុន្តែមានឯកសារជាច្រើន ដែលបង្ហាញអំពីទោសកំហុសរបស់ជនទាំងនេះដែលមានដូចជា ឯកសារដ៏សន្ធឹកសន្ធាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាបញ្ជាក់យ៉ាងលម្អិតអំពីសកម្មភាព និងមានសាក្សីជាច្រើនទៀតដែលអាចផ្តល់សក្ខីកម្មចំពោះការបង្កើត និងការដាក់អនុវត្តនូវសកម្មភាពរបស់ជនទាំងនេះ ។ ដូច្នេះហើយតុលាការនេះ ផ្តល់ឱកាសដ៏មានសារសំខាន់ដើម្បីបើកចំហរនិងវិភាគថា តើមេដឹកនាំទាំងនេះសម្រេចសេចក្តីយ៉ាងណា ដែលបណ្តាលឲ្យមនុស្សជិតពីរលាននាក់ត្រូវបាត់បង់ជីវិតនោះ ។ ករណី០០២នេះ នឹងផ្តល់នូវចម្លើយចំពោះចម្ងល់ជាច្រើនទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យដែលជនរងគ្រោះបានរង់ចាំអស់រយៈពេលជាយូរមកហើយនោះ ។ លើសពីនេះទៅទៀត ករណីនេះដែរក៏នឹងផ្តល់នូវយុត្តិធម៌និងការធូរស្បើយចំពោះការឈឺចាប់ និងទុក្ខវេទនាទាំងឡាយរបស់ជនរងគ្រោះកម្ពុជា តាមរយៈការដាក់ទោសចំពោះបុគ្គលដែលត្រូវទទួលខុសត្រូវទាំងនេះ ។